# ការឡើងថ្លៃម្ហូបអាហារ
# ផលប៉ះពាល់ ការលានុវត្តភាព បញ្ហាប្រឈម

## សេចក្តីផ្តើម

ប្រទេសកម្ពុជាបានរងផលប៉ះពាល់ពីអតិផរណាឡើងខ្ពស់ ដែលធ្វើឱ្យតម្លៃម្ហូបអាហារបានកើនឡើង ២៤,២ ភាគរយ ក្នុងចន្លោះពីខែ មករា ឆ្នាំ ២០០៧ ដល់ ខែមករា ឆ្នាំ ២០០៨។ អតិផរណាឡើងខ្ពស់ ហើយជាពិសេសការឡើងថ្លៃម្ហូបអាហារនាពេលថ្មីៗនេះ ចោទជាបញ្ហាធ្ងន់ធ្ងរ និងស្មុគស្មាញ សម្រាប់ប្រទេសកម្ពុជា ដោយសារបញ្ហានេះបង្កើតឱ្យមានបញ្ហាប្រឈមធំៗ ជាច្រើនចំពោះស្ថេរភាព សង្គម-សេដ្ឋកិច្ច ដែលអាចធ្វើឱ្យខូចខាតដល់ឱកាសជោគជ័យក្នុងការស្តារឡើងវិញនូវការត្រៀមលក្ខណៈ នៃកំណើនសេដ្ឋកិច្ចរឹងមាំ និងអត្រាអតិផរណាកម្រិតទាប ដែលប្រទេសកម្ពុជាធ្លាប់ទទួលបានក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងទៅ។

ការសង្កេត កង្វល់ និង អនុសាសន៍ ដែលបានរៀបរាប់ជាសង្ខេបខាងក្រោម ត្រូវបានលើក ឡើងក្នុងពេលប្រជុំនានា ដែលធ្វើដោយអង្គការមិនមែនរដ្ឋាភិបាល ក្រោមប្រធានបទស្តីពីការឡើងថ្លៃម្ហូបអាហារ ដើម្បីត្រៀមរៀបចំសម្រាប់វេទិកាពិភាក្សាស្តីពីអតិផរណា និងភាពក្រីក្រក្នុងប្រទេសកម្ពុជា ដែលប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ ២០០៨ ហើយក្នុងនោះតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា អង្គការស្រាវជ្រាវ ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល បានផ្លាស់ប្តូរទស្សនៈយោបល់លើប្រធានបទនេះ។ មិនតែប៉ុណ្ណោះ អង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញជូននូវសេក្តីថ្លែងការណ៍របស់ខ្លួនស្តីពីការឡើងថ្លៃម្ហូបអាហារផងដែរ។ ទស្សនៈទាំងអស់ដែលឆ្លុះបញ្ចាំងក្នុងឯកសារនេះ បានដកស្រង់ចេញពី កិច្ចពិភាក្សាផ្សេងៗក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដែលជាសមាជិក និងមិនមែនជាសមាជិករបស់បណ្តាញអង្គភាពពាណិជ្ជកម្មនិងសេដ្ឋកិច្ចរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

## សូចនាករតាមដានរួមគ្នា

មិនមានសូចនាករពិនិត្យតាមដានរួមគ្នាណាមួយពាក់ព័ន្ធនឹងអតិផរណាទេ។

## សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

| ចំណុច | ខ្លឹមសារ |
|---|---|
| ៤.១ | ព្យាករណ៍អតិផរណា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (គិតជា %): ៣,៥ ភាគរយសម្រាប់ព្យាករណ៍ឆ្នាំ ២០០៦ និង ៣ ភាគរយ ក្នុងមួយឆ្នាំសម្រាប់ព្យាករណ៍ឆ្នាំ ២០០៧-២០១០ |
| ៤.១ | គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធានាឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង រក្សាកំណើនអត្រាអតិផរណាក្រោម ៥ ភាគរយ |

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ បញ្ជាក់ថា ខណៈដែលមុំកំណើនមាន សារៈសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា បរិយាកាសសេដ្ឋកិច្ច សង្គម និង នយោបាយ ដែលមានស្ថេរភាព គឺជាកត្តាអនុគ្រោះដែលទ្រទ្រង់កំណើន និងការអភិវឌ្ឍន៍។ ដើម្បីធានាឱ្យមាន បរិយាកាសអំណោយផលដល់ម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចដែល មានស្ថេរភាពក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា យល់ឃើញថាការកំណត់អត្រាអតិផរណាឱ្យនៅ ក្រោម ៥ ភាគរយក្នុងមួយឆ្នាំ ចាប់ពី ឆ្នាំ ២០០៦ ដល់ ឆ្នាំ ២០១០ មានសារៈសំខាន់ណាស់។

បើទោះជាមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការរក្សាអត្រាអតិផរណាឱ្យនៅទាប ក៏ដោយ ក៏ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះពីការឡើងថ្លៃទំនិញ និងប្រេងឥន្ធនៈ ដូចបណ្តាប្រទេសដទៃទៀតនៅក្នុងពិភពលោក ហើយទទួលរងការប៉ះពាល់ពីការកើនឡើងនូវអតិផរណា ពី ៤,៧ ភាគរយ ក្នុងឆ្នាំ ២០០៦ ដល់ ១៨,៧ ភាគរយ ក្នុងចន្លោះពីខែ មករា ឆ្នាំ ២០០៧ ដល់ ខែមករា ឆ្នាំ ២០០៨ ហើយបន្តឡើងខ្ពស់បំផុតក្នុងពាក់កណ្តាលដើមឆ្នាំ ២០០៨ រហូតដល់ ២៥,១ ភាគរយ ហើយ បន្ទាប់មក បានធ្លាក់ចុះមកត្រឹម ២២ ភាគរយ ក្នុងខែ កក្កដា និង សីហា នៅក្នុងឆ្នាំដដែល[១] ។ បាតុភូតនៃ អតិផរណាខ្ពស់នេះបណ្តាលមកពីការកើនឡើងនៃតម្រូវការស្បៀងអាហារក្នុងស្រុក និងលើពិភពលោក និងការកើនឡើងថ្លៃប្រេងឥន្ធនៈ។ បាតុភូតនៃការកើនឡើងថ្លៃម្ហូបអាហារក្នុងប្រទេសកម្ពុជា បានបង្កើតឱ្យមានផលប៉ះពាល់អវិជ្ជមានផង និងកាលានុវត្តភាពផងដល់ប្រទេសនេះ។

**ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ និង បញ្ហាពាក់ព័ន្ធ**

យោងតាមស្ថិតិ ប្រជាជនក្រីក្របំផុត ៤០ ភាគរយ ចំណាយ ៧០ ភាគរយនៃការចំណាយសរុប របស់ពួកគេលើម្ហូបអាហារ (អង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០០៤) និង គ្រួសារនៅជនបទ ៦៥ ភាគរយ (រួមមាន អ្នកគ្មានដីធ្លី ២០ ភាគរយ និងអ្នកមានដីធ្លីបន្តិចបន្តួច ២៣ ភាគរយ[២]) អាចផលិតស្រូវត្រឹមតែគ្រប់ល្មមសម្រាប់បរិភោគក្នុងរយៈពេលមួយឆ្នាំប៉ុណ្ណោះ ឬ មិនគ្រប់សម្រាប់មួយឆ្នាំផង។ ប្រការនេះមានន័យថាគ្រួសារនៅជនបទភាគច្រើនបំផុត ត្រូវទិញស្បៀងបន្ថែមដើម្បីបំពេញតម្រូវការបរិភោគរបស់ពួកគេ។ ប៉ុន្តែ តម្លៃមុខទំនិញអាហារបានកើតឡើងយ៉ាងគំហុក។ តម្លៃអង្ករគ្រប់ប្រភេទបានកើនឡើងប្រហែល ១០០ ភាគរយ ក្នុងចន្លោះពីខែ ឧសភា ឆ្នាំ ២០០៧ ដល់ខែ ឧសភា ឆ្នាំ ២០០៨។ តម្លៃសាច់បានកើនឡើងទៅដល់ ៥០-៧០ ភាគរយ និង ត្រីនិងបន្លែកើនឡើង ២០-៣០ ភាគរយក្នុងអំឡុងពេលដដែលនេះ។

ជាលទ្ធផល ក្រុមអ្នកទិញម្ហូបអាហារសុទ្ធ ដូចជាកម្មករដែលមានប្រាក់ខែថេរ អ្នកគ្មានដីធ្លី និង អ្នកក្រីក្រ ត្រូវបានសង្កេតឃើញថាបានរងការប៉ះពាល់ខ្លាំងពីការកើនឡើងថ្លៃម្ហូបអាហារ ជាពិសេស សហគមន៍នេសាទរងការប៉ះពាល់កាន់តែធ្ងន់ធ្ងរដោយសារផលនេសាទធ្លាក់ចុះ ឯតម្លៃត្រីកើនឡើង ត្រឹមតែ ២០-៣០ ភាគរយ តិចជាងគេធៀបទៅនឹងទំនិញផ្សេងទៀតនៅលើទីផ្សារ។ ស្របជាមួយគ្នា តាមការសិក្សាស្តីពីការចាកចេញពីភាពក្រីក្រ (CDRI ឆ្នាំ ២០០៧) បានឱ្យដឹងថាភាពក្រីក្របានកើនឡើង រវាងឆ្នាំ ២០០១ និងឆ្នាំ ២០០៤ ក្នុងភូមិចំនួនបីក្នុងចំណោមភូមិដែលបានធ្វើការស្ទង់មតិ ទាំង ៩ ដែល ពឹងអាស្រ័យលើធនធានធម្មជាតិ មានដូចជា នេសាទ និង រុក្ខាប្រមាញ់។ អ្នកធ្វើគោលនយោបាយ គប្បីយកចិត្តទុកដាក់ជាពិសេសលើបញ្ហារបស់ជនក្រីក្រទាំងនេះឱ្យបានច្រើនបំផុត។

តម្លៃម្ហូបអាហារឡើងថ្លៃបង្ខំអ្នកក្រីក្រឱ្យអនុវត្តយុទ្ធសាស្ត្រទប់ទល់នឹងស្ថានភាពដ៏លំបាកនេះ ដូចជាការ កាត់បន្ថយបរិមាណអាហារ ការបរិភោគអាហារមិនសូវមានជីវជាតិ ការកាត់បន្ថយ ការចំណាយលើការអប់រំនិងសុខភាព ចំណាកស្រុក និង ការលក់ទ្រព្យសម្បត្តិ។ លើសពីនេះទៅទៀត ដើម្បីដោះស្រាយកាលៈទេសៈនៃតម្លៃម្ហូបអាហារខ្ពស់ដ៏លំបាកបែបនេះ គ្រួសារក្រីក្របានចាប់ផ្តើមខ្ចី បំណុល។ ក្នុងចំណោមគ្រួសារ ៣២ ភាគរយ បានជាប់ជំពាក់បំណុលថ្មីក្នុងដើមពាក់កណ្តាលឆ្នាំ ២០០៨ ដែលក្នុងនោះគ្រួសារជាង ៦០ ភាគរយ បានប្រើប្រាក់កំចីទាំងនេះដើម្បីទិញម្ហូបអាហារ ចំណាយលើ សុខភាព និង ទិញធាតុចូលកសិកម្ម។

ចំណុចទាំងអស់នេះឆ្លុះបញ្ចាំងថាការឡើងថ្លៃម្ហូបអាហារបានគម្រាមដល់កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រទេសកម្ពុជាមិនអាចសម្រេចគោលបំណងនិងគោលដៅក្នុង យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។

---

[១] ទិន្នន័យសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់របស់ក្រសួងផែនការ និង របាយការណ៍ពីធនាគារជាតិកម្ពុជា។

[២] គ្រួសារដែលមានដីកសិកម្មតិចជាងកន្លះហិកតា។

**កាលានុវត្តភាព និងបញ្ហាប្រឈមដែលនៅសេសសល់**

ទោះបីជាតម្លៃម្ហូបអាហារឡើងថ្លៃបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានខ្លះក៏ដោយ ក៏ស្ថានភាពនេះ នៅតែផ្តល់ឱកាសឱ្យប្រទេសកម្ពុជាបានទទួលអត្ថប្រយោជន៍ពីអតិផរណាលើម្ហូបអាហារនេះ ប្រសិនបើគោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពសមស្របណាមួយ ត្រូវបានយកមកប្រើប្រាស់ដើម្បី ជម្រុញការអភិវឌ្ឍវិស័យកសិកម្ម។

ទន្ទឹមនឹងតម្លៃម្ហូបអាហារឡើងថ្លៃ ថ្លៃដើមផលិតកម្មកសិកម្មក៏កើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ ផងដែរ។ ដោយសារតម្លៃប្រេងសាំងបានកើនឡើង ៥០ ភាគរយ ប្រេងម៉ាស៊ូតឡើងថ្លៃ ៨០ ភាគរយ និង តម្លៃពលកម្មប្រចាំថ្ងៃក៏បានកើនឡើងពី ៤០-៥០ភាគរយ ចាប់ពីខែ ឧសភា ឆ្នាំ ២០០៧ មកដល់ខែ ឧសភា ឆ្នាំ ២០០៨ កត្តាទាំងនេះបានជម្រុញឱ្យការចំណាយលើការភ្ជួររាស់រៀបចំដីស្រែបានកើនឡើង ដល់ ៣៥ ភាគរយ។ លើសពីនេះ តម្លៃដីគឺមីបានកើនឡើងដល់ទៅ ៨០-២០០ ភាគរយក្នុងរយៈពេល ដដែល[៣]។ ទោះជាមានការកើនឡើងថ្លៃដើមផលិតកម្មក៏ដោយ កសិករនៅតែអាចទទួលផលចំណេញ ៣២ ភាគរយ ពីកសិកម្មរបស់ពួកគេ (CDRI សេចក្តីសង្ខេបគោលនយោបាយ ឆ្នាំ ២០០៨)។ ជាជំនួស ថ្លៃដើមផលិតកម្មខ្ពស់ រួមទាំងតម្លៃដីគីមីផង ផ្តល់ឱកាសឱ្យកសិកម្មកម្ពុជាប្រើប្រាស់វិធីសាស្ត្រ បច្ចេកទេសមានកម្រិតបានលឿន ដូចជាបច្ចេកទេសកសិកម្មសរីរាង្គ និង ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-១០។

ស្ថិតក្នុងលក្ខខណ្ឌដែលប្រទេសកម្ពុជាគឺជាប្រទេសកសិកម្ម និងជាប្រទេសនាំចេញកសិផល (ស្រូវ និងកសិផលដទៃទៀត) ការឡើងថ្លៃម្ហូបអាហារត្រូវបានគេមើលឃើញជាឱកាសមាសមួយ សម្រាប់ប្រទេសនេះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនតាមទីជនបទ ដែលមានចំនួន ៩១ ភាគរយនៃអ្នកក្រីក្ររស់នៅពឹងផ្អែកលើកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ម្យ៉ាងវិញទៀត កសិដ្ឋាន តូចៗអាចមានផលិតភាពខ្ពស់ជាងកសិដ្ឋានធំៗ (ធនាគារពិភពលោក ឆ្នាំ ២០០៧) ហេតុនេះ កសិករខ្នាតតូចទំនងជារួមចំណែកក្នុងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានច្រើនជាង។ ប៉ុន្តែកាលានុវត្តភាព នេះអាចសម្រេចបាន លុះណាតែមានការសម្របសម្រួលដោយគោលនយោបាយសាធារណៈ និងសកម្មភាពរឹងមាំដែលអាចពុះពារបញ្ហាប្រឈមធំៗក្នុងវិស័យកសិកម្មបាន (CDRI ជិតចេញផ្សាយ)។

បញ្ហាប្រឈមដែលនៅសេសសល់ រួមមានបញ្ហាប្រជាជនគ្មានដីធ្លីនិងមានដីធ្លីតិចតួច ផលិតភាពទាប កសិកម្មពឹងផ្អែកលើទឹកភ្លៀង ភាពងាយរងគ្រោះដោយគ្រោះមហន្តរាយ និងបញ្ហាទីផ្សារ។ ក្នុងចំណោម ៤៦ ភាគរយនៃគ្រួសារនៅជនបទមិនមានដីធ្លី និងមានដីធ្លីតិចតួច (ធនាគារពិភពលោក ឆ្នាំ ២០០៦) គ្រួសារនៅជនបទត្រឹមតែ ៣៥ ភាគរយប៉ុណ្ណោះ អាចផលិតកសិផលស្រូវលើស (CDRI ជិតចេញផ្សាយ)។ ហើយដោយសារបញ្ហាដីធ្លីជាបញ្ហាសំខាន់ នៅក្នុងប្រទេសកម្ពុជា មានតែ ១៦ ភាគរយនៃ គ្រួសារក្រីក្របំផុតប៉ុណ្ណោះ ដែលមានដីធ្លីដែលបានធានាដោយប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) និង ៣៧ ភាគរយ ទៀតត្រូវបានធានាដោយឯកសារ (ប្លង់ទន់) (ក្រសួងផែនការ ខែ កុម្ភៈ ឆ្នាំ ២០០៦)។

ផលិតភាពនៃដំណាំស្រូវក្នុងប្រទេសកម្ពុជា ត្រូវបានកែលម្អបង្កើនពី ១,៣ តោនក្នុង ១ ហិកតា ក្នុងឆ្នាំ ១៩៩៣ ទៅដល់ប្រហែលជា ២ តោនក្នុង ១ ហិកតា ក្នុងឆ្នាំ ២០០៤-០៥ (ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-១០)។ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថាកំណើននេះ បានទទួលការជ្រោមជ្រែងពីការប្រើប្រាស់ពូជស្រូវផ្តល់ទិន្នផលខ្ពស់ច្រើនប្រភេទ និង បច្ចេកទេសកសិកម្មនិងការអនុវត្ត ប៉ុន្តែ ផលិតភាពនេះនៅមានកម្រិតទាបនៅឡើយ ប្រសិនបើប្រៀបធៀបជាមួយផលិតភាព ក្នុងប្រទេសជិតខាងដែលមានលក្ខខណ្ឌអាកាសធាតុដូចគ្នា។ ប្រការនេះមានន័យថាមានសក្តានុពល និងកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីបង្កើនផលិតភាពកសិកម្មរបស់ ប្រទេសកម្ពុជា។

---

[៣] CDRI (ខែ សីហា ឆ្នាំ ២០០៨) សេចក្តីព្រាងចុងក្រោយនៃការស្ទង់មតិជាតិស្តីពីផលប៉ះពាល់នៃតម្លៃម្ហូបអាហារឡើងថ្លៃ)។

បញ្ហាដែលទាក់ទងនឹងការធ្វើកសិកម្មអាស្រ័យទឹកភ្លៀង គឺជាការព្រួយបារម្ភដ៏ធំមួយ ហើយក៏ជាកត្តាកំណត់នៃកសិផលរបស់ប្រទេសកម្ពុជាផងដែរ។ កសិករខ្មែរភាគច្រើនអាចប្រមូលផលបានតែម្តងក្នុងមួយឆ្នាំ និងងាយរងគ្រោះដោយភាពរាំងស្ងួត ទឹកជំនន់ និងផលប៉ះពាល់របស់ថ្នាំសម្លាប់សត្វល្អិត។ ទិន្នន័យភាពក្រីក្ររបស់ប្រទេសកម្ពុជា (ក្រសួងផែនការ ខែកុម្ភៈ ឆ្នាំ ២០០៤) ពន្យល់ថាជាង ៩០ ភាគរយនៃគ្រួសារក្រីក្របំផុត ៤០ ភាគរយរបស់ប្រទេសកម្ពុជា កំពុងរស់នៅក្នុងភូមិដែលបានរងការប៉ះពាល់ដោយគ្រោះមហន្តរាយ ក្នុងរយៈកាលប្រាំឆ្នាំចុងក្រោយនេះ។ ជាងនេះទៅទៀត ភាពរង្វើលនៃការផលិតស្រូវក៏បណ្តាលមកពីកង្វះប្រព័ន្ធធារាសាស្ត្រដែរ។ ក្នុងឆ្នាំ ២០០៥ មានដីកសិកម្មត្រឹមតែ ២០ ភាគរយប៉ុណ្ណោះដែលមានប្រព័ន្ធស្រោចស្រព។

កត្តាទាំងអស់នេះសុទ្ធតែមានសារៈសំខាន់ចំពោះកសិកម្មរបស់ប្រទេសកម្ពុជា។ ទោះបីជាកសិករបានមើលឃើញសក្តានុពលដើម្បីទទួលបានផលកាន់តែ ច្រើនពីការធ្វើកសិកម្មរបស់ពួកគាត់ក្តី ក៏ការពឹងអាស្រ័យលើទឹកភ្លៀង និងភាពងាយរងគ្រោះដោយគ្រោះធម្មជាតិ ធ្វើឱ្យកសិករខ្នាតតូច និងកសិករខ្នាតធំ មានការស្ទាក់ស្ទើរក្នុងការវិនិយោគលើការទិញគ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់ និងធាតុចូលដែលមានតម្លៃថ្លៃដទៃទៀត។ ដូច្នេះ កាលានុវត្តភាពនៃតម្លៃម្ហូបអាហារឡើងថ្លៃអាចសម្រេចបានជោគជ័យ និងផ្តល់ផលប្រយោជន៍ ឱ្យប្រទេសកម្ពុជាបាន លុះត្រាណាតែបញ្ហាប្រឈមទាំងនេះ ត្រូវបានដោះស្រាយឱ្យបានត្រឹមត្រូវ។ ប៉ុន្តែ ការវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម ការអភិវឌ្ឍជនបទ និងការគ្រប់គ្រង ធនធានទឹក នៅមានកម្រិតទាប និងមិនមានថវិកាគ្រប់គ្រាន់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍ ជនបទ មានសមត្ថភាពចំណាយ ត្រឹមតែ ៥០ ភាគរយ និង ៧០ ភាគរយ នៃថវិកាសរុបក្នុងឆ្នាំ ២០០៧ (វេទិកានៃអង្គការ មិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សេចក្តីសង្ខេបថវិកា ខែ កញ្ញា ឆ្នាំ ២០០៨) ប៉ុណ្ណោះ។

លោក ឆាយ សារ៉ាត់ និង បងប្រុសរបស់គាត់ រស់នៅភ្នំពេញ ហើយមានស្រែនៅកំពង់ព្រាង ស្រុកសង្កែ ខេត្តបាត់ដំបង។ លោកសារ៉ាត់ បានមាន ប្រសាសន៍ថា "ក្នុងដី ១០ ហិកតា យើងលក់ស្រូវចំណេញបានប្រាក់ ២.០០០ ដុល្លារ ក្នុងរដូវប្រូតកាត់កាលពីឆ្នាំមុន"។

គាត់បានបន្តទៀតថា "ដោយសារគេឱ្យថ្លៃស្រូវខ្ពស់ យើងពង្រីកដីធ្វើស្រែ ដល់ទៅ ៤០ ហិកតាក្នុងឆ្នាំនេះ ប៉ុន្តែប្រហែលមិនសូវបានផលទេ ឬអាចអត់ចំណេញសោះផងក៏មិនដឹង ព្រោះដោយសារភាពរាំងស្ងួតតាំងពីសាបព្រួសហើយមកម្ល៉េះ។"

*បទសម្ភាសន៍ជាមួយលោក ឆាយ សារ៉ាត់ ២៧ តុលា ២០០៨*

## ការឆ្លើយតបរបស់រាជរដ្ឋាភិបាល និង បញ្ហាពាក់ព័ន្ធ

នៅក្នុងការឆ្លើយតបទៅនឹងអតិផរណា និងតម្លៃម្ហូបអាហារឡើងថ្លៃ រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការបន្ទាន់មួយចំនួន ដូចខាងក្រោម[៤]:

- ការឆ្លើយតបនៃគោលនយោបាយសារពើពន្ធ: លើកលែងពន្ធតម្លៃបន្ថែម (VAT) និង កាត់បន្ថយកាតព្វកិច្ចពន្ធនាំចូលលើវត្ថុធាតុដើមកសិកម្មដែលបាននាំចូល កម្រិតផលប៉ះពាល់លើអ្នកប្រើប្រាស់ដោយសារតម្លៃប្រេងសាំងពិភពលោកឡើងថ្លៃ កាត់បន្ថយពន្ធលើការនាំចូល ប្រេងសាំង ដែលធ្វើឱ្យបាត់បង់ចំណូលថវិកាជាតិ ២៤០ លានដុល្លារ ឧបត្ថមធនអគ្គីសនីកម្ពុជា បាន ៤១ លានដុល្លារ។

[៤] សន្ទរកថាដោយ បណ្ឌិត ហង្ស ជួនណារ៉ុន ថ្លែងនៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីតម្លៃម្ហូបអាហារឡើងថ្លៃ និង ការឆ្លើយតប នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ នៅ CJCC និង ផលប៉ះពាល់នៃតម្លៃម្ហូបអាហារឡើងថ្លៃ (CDRI, ជិតចេញផ្សាយ)។

- កម្មវិធីសកម្មភាពប្រយុទ្ធនឹងសម្ពាធអតិផរណាឡើងខ្ពស់: ហាមឃាត់ការនាំចេញស្រូវរយៈពេល ២ ខែ និងផ្តល់កម្ចីការប្រាក់ទាបសម្រាប់ពាណិជ្ជករ/រោងម៉ាស៊ីនកិនស្រូវ ដើម្បីទិញស្រូវស្តុក ទុកឱ្យបានកាន់តែច្រើន សម្រាប់ទីផ្សារក្នុងស្រុក និងលក់អង្ករក្នុងតម្លៃឧបត្ថម្ភធនជូនប្រជាជន នៅទីក្រុង។
- ការឆ្លើយតបនៃគោលនយោបាយរូបិយវត្ថុ: បម្រុងរូបិយវត្ថុទ្វេដង និង ធ្វើឱ្យអត្រាប្តូរប្រាក់មាន ស្ថេរភាព។
- វិធានការរដ្ឋបាល: ប្រាក់បៀវត្សរ៍មូលដ្ឋាន និង ប្រាក់ឧបត្ថម្ភគ្រួសារ ត្រូវបានតម្លើងឱ្យមន្ត្រី រាជការ និង អ្នកចូលនិវត្តន៍ និង បង្កើនប្រាក់ឈ្នួលកម្មករកាត់ដេរ។

សរុបសេចក្តីមក អង្គការមិនមែនរដ្ឋាភិបាល សូមសម្តែងនូវការកោតសរសើរដ៏ខ្ពង់ខ្ពស់ចំពោះ ការយកចិត្តទុកដាក់ និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះអតិផរណាខ្ពស់ និងជាពិសេស ចំពោះតម្លៃម្ហូបអាហារឡើងថ្លៃ។ វិធានការតម្លើងប្រាក់បៀវត្សរ៍មូលដ្ឋាន និងប្រាក់ឧបត្ថម្ភគ្រួសារ សម្រាប់បុគ្គលិកស៊ីវិលត្រូវបានស្វាគមន៍ជាពិសេស ដោយសារប្រាក់បៀវត្សរ៍បច្ចុប្បន្នមានកម្រិតទាប និងប្រហែលជា ១២ ភាគរយនៃមន្ត្រីរាជការ (ក្រសួងផែនការ ខែ កុម្ភៈ ឆ្នាំ ២០០៦) ស្ថិតក្នុងភាពក្រីក្រ។ វិធានការនេះឆ្លុះបញ្ចាំងបន្ថែមពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់។ ទោះបីជា ប្រាក់បន្ថែម ៦ ដុល្លារក្នុងមួយខែសម្រាប់កម្មករ កាត់ដេរ មិនអាចធៀបទៅនឹងអត្រាអតិផរណាក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលសូមសម្តែងនូវការ កោតសរសើរជាថ្មីម្តងទៀតចំពោះបទអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែ យើងខ្ញុំមានការសោក ស្តាយដែលរដ្ឋាភិបាលមិនបានប្រើយន្តការដើម្បីធានាឱ្យបានថារោងចក្រកាត់ដេរនៅទូទាំងប្រទេសពិតជាអនុវត្តការបន្ថែមប្រាក់ឈ្នួលគ្រប់តាមចំនួនកំណត់។

វិធានការលើកលែងពន្ធតម្លៃបន្ថែម VAT និងកាត់បន្ថយកាតព្វកិច្ចពន្ធនាំចូលលើវត្ថុធាតុដើម កសិកម្មដែលបាននាំចូល មានសារៈសំខាន់បំផុតសម្រាប់ការគាំទ្រដល់កសិករ។ ប៉ុន្តែ វិធានការទាំងនេះ ត្រូវបានរំពឹងថានឹងធ្វើឱ្យកសិករទាំងអស់ពេញចិត្ត ហើយកសិករជាអ្នកមានឬខ្នាតធំ ទំនងជាទទួលបាន ផលប្រយោជន៍ច្រើនជាង ដោយសារពួកគេប្រើវត្ថុធាតុដើមទាំងនេះច្រើនជាងកសិករខ្នាតតូច ឬ កសិករ ក្រីក្រ។ តាមទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាល ដោយសារធនធានរបស់រដ្ឋាភិបាលមានកម្រិត និង ដោយសារអ្នកក្រីក្រទទួលរងផលប៉ះពាល់ធ្ងន់ជាងគេបំផុតពីអតិផរណា អន្តរាគមន៍របស់រាជរដ្ឋាភិបាល គប្បីផ្តោតលើប្រជាពលរដ្ឋក្រីក្រ ដើម្បីឱ្យវិធានការកាន់តែមានលក្ខណៈល្អប្រសើរជាងនេះទៅទៀត។ បទអន្តរាគមន៍នេះអាចទៅដល់កសិករខ្នាតតូច តាមរយៈយន្តការនានា ដូចជាសមាគមកសិករ សហករណ៍កសិករ និងក្រុមសហគមន៍ដទៃទៀត ដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ ២០០៦-១០ បានទទួលស្គាល់ថាមានសារៈសំខាន់ និងប្រសិទ្ធិភាព។

ប៉ុន្តែ ដើម្បីបង្កើនប្រាក់ចំណេញរបស់កសិករ និង ដើម្បីជៀសវាងការប្រើប្រាស់ថ្នាំសម្លាប់ សត្វល្អិតច្រើនហួសកំណត់ រាជរដ្ឋាភិបាលកម្ពុជាគប្បីពិនិត្យមើល និង មានវិធានការលើកទឹកចិត្តឱ្យប្រើ ប្រាស់វិធីសាស្ត្រដែលប្រើធាតុចូលតិច និងមានតម្លៃទាបសម្រាប់ការធ្វើកសិកម្ម ដូចជាប្រព័ន្ធស្រូវប្រពលវប្បកម្ម (SRI)។ ទន្ទឹមនឹងនេះ ដោយសារប្រទេសកម្ពុជាមានសក្តានុពលកសិកម្មសរីរាង្គ រាជរដ្ឋាភិបាលកម្ពុជា ក៏គប្បីជម្រុញការនាំចេញផលិតផលដែលមានទីផ្សារពិសេសរបស់ខ្លួន ដូចជាកសិផលសរីរាង្គ ជាដើម (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០)។ ដោយធ្វើបែបនេះ ការឡើងថ្លៃជីគីមីនឹងផ្តល់ឱកាសឱ្យប្រទេសកម្ពុជា និងកសិកររបស់ខ្លួន ដើម្បីផ្តោតជាសំខាន់លើប្រព័ន្ធស្រូវប្រពលវប្បកម្ម និង កសិកម្មសរីរាង្គ ដែលអាចអនុញ្ញាតឱ្យពួកគេអាចជៀសផុតពីការចំណាយចរិកាច្រើន និង អាចបង្កើនផលចំណេញ ខណៈដែលនិរន្តរភាពដី និង បរិស្ថានត្រូវបានរក្សាក្នុងពេលទន្ទឹមគ្នានេះដែរ។ ប្រការនេះមានន័យថា បទអន្តរាគមន៍ចំពោះការកាត់បន្ថយតម្លៃជីគីមី មិនមែនជាជម្រើសដ៏ល្អបំផុតទេ ប៉ុន្តែការពិចារណាចំពោះការពុះពារជំនះឧបសគ្គដទៃទៀតក្នុងវិស័យកសិកម្មនឹងកាន់តែមានប្រយោជន៍ ដូចជាធារាសាស្ត្រខ្នាតតូច ការពង្រីកប្រព័ន្ធស្រូវប្រពលវប្បកម្ម និងកសិកម្មសរីរាង្គ ការពង្រឹងនិងពង្រីកក្រុមសហគមន៍ ដូចជាសមាគមន៍កសិករ និង សហករណ៍កសិករ ក្រុមសន្សំ ធនាគារស្រូវ ក្រុមប្រើ ប្រាស់ទឹក និង ក្រុមផ្សេងៗទៀត។

ដោយសារការឡើងថ្លៃប្រេងសាំងគឺជាកត្តាមួយនៃអតិផរណា វិធានការរបស់រាជរដ្ឋាភិបាលក្នុង ការកាត់បន្ថយពន្ធលើការនាំចូលប្រេងសាំង យ៉ាងហោចណាស់ក៏ជាជម្រើសមួយនៃការដោះស្រាយបញ្ហា ដើម្បីទប់ទល់នឹងអតិផរណាខ្ពស់ផងដែរ។ ពិតប្រាកដណាស់ ការឡើងថ្លៃប្រេងសាំងជម្រុញឱ្យតម្លៃទំនិញ ដទៃទៀតកើនឡើង រួមទាំងតម្លៃកសិផលផងដែរ។ ទោះបីយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាល យល់ឃើញថាវិធានការនេះទំនងជាផ្តល់ផលប្រយោជន៍ដល់អ្នកមានច្រើនជាងអ្នកក្រីក្រ ដោយសារអ្នកមានបំផុតបានចំណាយ ១២,៤ ភាគរយនៃចំណាយរបស់ពួកគេទៅលើមធ្យោបាយធ្វើដំណើរ និងគមនាគមន៍ ច្រើនជាងអ្នកក្រីក្របំផុត ២០ ដង (អង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០០៤)។

ឧបត្ថម្ភធនក្នុងទឹកប្រាក់ ៤១ លានដុល្លារ ទៅឱ្យអគ្គិសនីកម្ពុជា មានលក្ខណៈលំអៀងចំពោះ អ្នកមាន និងអ្នកទីក្រុងជាខ្លាំង។ តាមស្ថិតិ អ្នកក្រីក្រត្រឹមតែ ១ ភាគរយប៉ុណ្ណោះ រស់នៅទីក្រុងភ្នំពេញ (ក្រសួងផែនការ ខែ កុម្ភៈ ឆ្នាំ ២០០៦) ហើយការប្រើប្រាស់អគ្គិសនីរបស់ពួកគេតិចតួចខ្លាំងណាស់ មិនអាចប្រៀបទៅនឹងអ្នកមានបានទេ។ ទោះបីការអះអាងនេះអាចបញ្ជាក់ថាឧបត្ថម្ភធន អាចរក្សាភាពប្រកួតប្រជែងរបស់ឧស្សាហកម្មក៏ដោយ ក៏តម្លៃមធ្យោបាយដឹកជញ្ជូន និងតម្លៃទឹកភ្លើង មិនមែនជា កត្តាតែមួយគត់សម្រាប់កំណត់ភាពក្រកួតប្រជែងតម្លៃទំនិញរបស់ប្រទេសកម្ពុជាទេ។ ម៉្យាងវិញទៀត ការលក់អង្ករក្នុងតម្លៃឧបត្ថម្ភធន ក៏គ្រាន់តែផ្តល់ផលប្រយោជន៍ដល់អ្នកក្រីក្រនៅទីក្រុងប៉ុណ្ណោះ ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ជាទូទៅ អង្គការមិនមែនរដ្ឋាភិបាលស្វាគមន៍ចំពោះការគិតគូរពិចារណា និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាអតិផរណាឡើងខ្ពស់ជាទូទៅ និងតម្លៃម្ហូបអាហារឡើងថ្លៃ។ ប៉ុន្តែ យើងសង្កេតឃើញថា ខណៈដែលវិធានការខ្លះអាចដោះស្រាយការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចទាំងមូល វិធានការដទៃទៀតទំនងជាផ្តល់ផលប្រយោជន៍ដល់ប្រជា-ជនទីក្រុងនិងអ្នកមាន ច្រើនជាងអ្នកក្រីក្រនៅ ជនបទដែលភាគច្រើនរងផលប៉ះពាល់ដោយអតិផរណា និងតម្លៃម្ហូបអាហារឡើងថ្លៃ។ ប្រការនេះមានន័យថា ការឆ្លើយតបរបស់រដ្ឋាភិបាលមិនទាន់មានប្រសិទ្ធិភាព ក្នុងការចូលទៅឱ្យដល់ក្រុមអ្នករងគ្រោះបំផុតនៅឡើយទេ។

- តាមគោលការណ៍ តម្លៃម្ហូបអាហារឡើងថ្លៃហាក់បីដូចជាកាលានុវត្តភាពនិងសក្តានុពលសម្រាប់ ការកាត់បន្ថយភាពក្រីក្រនៅជនបទរបស់ប្រទេសកម្ពុជា។ ដើម្បីធានាឱ្យបាននូវការធ្វើឱ្យសម្រេច សក្តានុពលទាំងនេះ អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់អនុសាសន៍ ដូចខាងក្រោមៈ
- ទោះបីជាដីស្រែត្រូវបានបង្កើនក្តី ក៏ម្រិតផលិតភាពបច្ចុប្បន្ននៅតែត្រូវកែលម្អបន្ថែមទៀតដែរ។ ខណៈដែលផលិតភាពអាចត្រូវបានបង្កើនតាមរយៈការជ្រើសរើសពូជដែលផ្តល់ទិន្នផលខ្ពស់ និងការកែលម្អបច្ចេកទេសកសិកម្ម ក៏គប្បីមានការយកចិត្តទុកដាក់ចំពោះប្រពលវប្បកម្ម និងពិពិធកម្មកសិកម្ម។ ដូចច្នេះ គេចាំបាច់ត្រូវមានការវិនិយោគបន្ថែមក្នុងការសិក្សាស្រាវជ្រាវ និង វិបុលកម្មកសិកម្ម។
- ដោយសារកសិដ្ឋានខ្នាតតូចត្រូវបានបង្ហាញថាមានផលិតភាពខ្ពស់ជាងកសិដ្ឋានខ្នាតធំ និងដោយសារគ្រួសារនៅជនបទគ្មានដីធ្លីមានចំនួនច្រើន ការផ្តល់ដីសម្បទានសង្គមកិច្ចក្នុងកម្មវិធី កំណែទម្រង់ដីធ្លី គប្បីត្រូវបានរក្សាជារបៀបវារៈអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន។ ម៉្យាងវិញទៀត កម្មសិទ្ធិដីធ្លីនៅតែងាយរង ផលប៉ះពាល់ចំពោះប្រជាជនភាគច្រើន។ ដូចច្នេះ ការពន្លឿនការចេញប័ណ្ណកម្មសិទ្ធិដីធ្លី (ប្លង់រឹង) ឱ្យដល់ប្រជាជននៅជនបទគឺជាអាទិភាពចម្បងមួយសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។
- ដើម្បីកាត់បន្ថយការពឹងអាស្រ័យលើទឹកភ្លៀង និងដើម្បីធ្វើប្រពលវប្បកម្មនៃការប្រើប្រាស់ ដីកសិកម្ម ច្បាស់ណាស់ថាវាទាមទារឱ្យមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ដើម្បីបង្កើនការវិនិយោគពិតប្រាកដ ក្នុងការគ្រប់គ្រងធនធានទឹក និង ការពង្រីកប្រព័ន្ធធារាសាស្ត្រ។ ការបង្កើនការវិនិយោគក្នុងការអភិវឌ្ឍជនបទ ក៏ជាអាទិភាពមួយទៀត សម្រាប់ការកសាងផ្លូវជនបទ និង ការកសាងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។

- ស្ថិតក្នុងស្ថានភាពងាយរងគ្រោះដោយគ្រោះធម្មជាតិ ដូចជាទឹកជំនន់ និងភាពរាំងស្ងួត សូមអំពាវនាវ ជាពិសេសឱ្យមានការពង្រឹងការគ្រប់គ្រងគ្រោះមហន្តរាយតាមរយៈការបង្កើត យន្តការដើម្បីកាត់បន្ថយឬសម្រាលហានិភ័យដូចជា កម្មវិធីត្រៀមលក្ខណៈ ជាដើម។ម៉្យាងវិញទៀត ភាពងាយរងគ្រោះអាចត្រូវបានដោះស្រាយតាមរយៈការបង្កើនកម្មវិធីកិច្ចការពារផ្នែក សង្គម។
- ដោយសាររាជរដ្ឋាភិបាលបានអនុវត្តវិធានការជាច្រើន ដើម្បីដោះស្រាយបាតុភូតអតិផរណា អង្គការមិនមែនរដ្ឋាភិបាល សូមសំណូមពរដល់រាជរដ្ឋាភិបាលឱ្យពិនិត្យឡើងវិញនូវរាល់វិធានការ ដែលបានប្រើកន្លងមក ដើម្បីសិក្សាឱ្យបានដឹង ថាតើវិធានការទាំងនោះមានប្រសិទ្ធិភាពសម្រាប់ កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រដែរឬទេ។ អង្គការមិនមែនរដ្ឋាភិបាលសូម អំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បន្តប្រើវិធានការកំណត់គោលដៅដែលអាចដោះស្រាយបញ្ហានិងកង្វល់របស់អ្នកក្រីក្រដោយផ្ទាល់ ជាពិសេស តាមរយៈយន្តការក្រុមសហគមន៍នានា ដូចជាសមាគមន៍កសិករ និងសហករណ៍កសិករ ធនាគារស្រូវ ក្រុមអ្នកប្រើប្រាស់ទឹក ក្រុមសន្សំ ក្រុមអ្នកនេសាទ និង ក្រុមផ្សេងៗទៀត។

**ព័ត៌មានទំនាក់ទំនង**

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង :


**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា :**

**កម្មវិធីបញ្ហាអភិវឌ្ឍន៍**

**លោក ង៉ោ សុថាត** ប្រធានសម្របសម្រួលកម្មវិធីបញ្ហាអភិវឌ្ឍន៍

ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩

ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉ែលៈ sothath@ngoforum.org.kh

គេហទំព័រៈ http://www.ngoforum.org.kh

អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ខ័ណ្ឌចំការមន

ប្រអប់សំបុត្រលេខ ២២៩៥ រាជធានីភ្នំពេញ។